វិទ្យាស្ថានសភាកម្ពុជា
PARLIAMENTARY INSTITUTE OF CAMBODIA
STRENGTHENING PARLIAMENTARY CAPACITY

# ព្រឹត្តប័ត្រព័ត៌មានសង្ខេប

**សប្តាហ៍ដែលបញ្ចប់**
**ថ្ងៃទី២៩ ខែ មីនា ២០១៨**

ចំណុចសំខាន់ៗ អំពីព័ត៌មានសេដ្ឋកិច្ច និងការអភិវឌ្ឍសារពើពន្ធនៅក្នុងបណ្តាប្រទេសជាសមាជិកអាស៊ាន និងនៅប្រទេសផ្សេងៗទៀត នៅក្នុងសប្តាហ៍នេះ គឺៈ

- ព្រឹត្តិការណ៍ ខួបលើកទី៣៩ នៃការដាក់ឲ្យចរាចរប្រាក់រៀលឡើងវិញ
- មានការអំពាវនាវឱ្យមាន "ភាពជាដៃគូអឺរ៉ុប-ចិនដ៏រឹងមាំ" ក្នុងអំឡុងពេលដែលលោកប្រធានាធិបតីចិន ស៊ី ជីនពីង បានមកដល់ប្រទេសបារាំង
- អ្នកព្យាករណ៍សេដ្ឋកិច្ចមើលឃើញពីភាពនៅទ្រឹងនៃសេដ្ឋកិច្ចអាមេរិក ដែលនេះឆ្លុះបញ្ចាំងថាគោលនយោបាយពាណិជ្ជកម្ម និងការថយចុះនៃសេដ្ឋកិច្ចសកលលោក គឺជាហានិភ័យដ៏ធំបំផុត

*ព្រឹត្តប័ត្រសង្ខេបព័ត៌មាននេះ គឺជាព្រឹត្តិប័ត្រប្រចាំសប្តាហ៍ដែលរៀបចំឡើងដើម្បីតាមដានព័ត៌មានអំពីការអភិវឌ្ឍសេដ្ឋកិច្ច និងសារពើពន្ធថ្មីៗ នៅក្នុងប្រទេសកម្ពុជា និងដៃគូពាណិជ្ជកម្មនានា។ ឯកសារនេះត្រូវបានធ្វើឡើងដោយក្រុមការងារបណ្តុះ-បណ្តាលសមត្ថភាពការវិភាគសារពើពន្ធរបស់វិទ្យាស្ថានសភាកម្ពុជា ក្នុងគោលបំណងពង្រឹងជំនាញនៃការធ្វើឯកសារ និងការស្រាវជ្រាវរបស់ខ្លួន។ ការងារនេះត្រូវបានព្យាយាមធ្វើឡើងដើម្បីធានាថាការវិភាគ និងអត្ថន័យ ដែលបានផ្តល់នៅក្នុងឯកសារនេះ មានគុណភាពខ្ពស់។ ទោះជាយ៉ាងណាក៏ដោយ សូមអ្នកអានចាត់ទុកឯកសារនេះជាផ្នែកមួយនៃលំហាត់អនុវត្តនៅក្នុងកំឡុងពេលនៃការបណ្តុះបណ្តាល។ យើងមិនអាចធានាថាឯកសារនេះល្អឥតខ្ចោះនោះទេ។*

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### ព្រឹត្តិការណ៍ប្រារព្ធ ខួបលើកទី៣៩នៃការដាក់ឲ្យចរាចរប្រាក់រៀលឡើងវិញ

នៅសប្តាហ៍នេះ ធនាគារជាតិនៃកម្ពុជាបានប្រារព្ធធ្វើពិធីទិវាប្រាក់រៀលប្រចាំឆ្នាំដើម្បីរំលឹកឡើងវិញនូវការប្រើប្រាស់ប្រាក់រៀល។

ព្រឹត្តិការណ៍នេះរួមមាន ការប្រកួតប្រជែង និងការប្រកាសកម្មវិធីថ្មីៗ ដោយសហការជាមួយស្ថាប័នហិរញ្ញវត្ថុកម្ពុជា ព្រមទាំងការធ្វើសន្និសីទរបស់ធនាគារជាតិនៃកម្ពុជាដើម្បីអោយវាគ្មិនមានឱកាសពិភាក្សា និងចែករំលែកពីភាពជោគជ័យ ក៏ដូចជាបញ្ហាប្រឈមក្នុងការប្រើប្រាស់រូបិយ-ប័ណ្ណប្រាក់រៀលកន្លងមក។ កម្មវិធីនេះក៏មានការចូលរួមពីកម្មសិក្សាការីរបស់វគ្គបណ្តុះបណ្តាលសមត្ថភាពវិភាគសារពើពន្ធ (FACT) ផងដែរ។

សារព័ត៌មាន ភ្នំពេញប៉ុស្តិ៍បានចុះផ្សាយពីសន្ទរកថារបស់អគ្គទេសាភិបាលនៃធនាគារជាតិកម្ពុជា ឯកឧត្តម ជា ចាន់តូ ដែលជាអ្នកជំរុញឲ្យមានការប្រារព្ធ ខួបនៃការប្រើប្រាស់ប្រាក់រៀល បានបង្ហាញពីប្រវត្តិនៃបញ្ហារបស់រូបិយវត្ថុដែលកម្ពុជាបានជួបប្រទះបន្ទាប់ពីការរំដោះចេញពីរបបខ្មែរក្រហមនៅឆ្នាំ១៩៧៩ និងកិច្ចខិតខំប្រឹងប្រែងជាបន្តបន្ទាប់របស់ធនាគារជាតិនៃកម្ពុជា ក្នុងការដោះស្រាយបញ្ហាទាំងនោះ ដូចជាៈ

សម្រាប់ការធ្វើពាណិជ្ជកម្ម ឬដោះដូរទំនិញសម័យកាលនោះ តម្លៃនៅលើទីផ្សារដែលត្រូវកំណត់ដោយមាស និងអង្ករ ក្នុងខណៈពេលដែលរូបិយប័ណ្ណរបស់ប្រទេសជិតខាងត្រូវបានប្រើប្រាស់សម្រាប់ការទូទាត់នៅតាមបណ្តាខេត្តនានាដែលនៅជាប់ព្រំដែន។

ការដាក់ឱ្យចរាចរប្រាក់រៀលសារជាថ្មីបានទទួលនូវការសាទរ និងគាំទ្រយ៉ាងខ្លាំងពីប្រជាជន។ ការណែនាំឱ្យប្រើប្រាស់ ប្រាក់រៀល ទទួលបានជោគជ័យ ព្រោះប្រជាជនមានការចង់ដឹង ពួកគេចង់ឃើញ ចង់កាន់ក្រដាសប្រាក់ថ្មី ដើម្បីឲ្យពួកគេមានភាពជឿជាក់បន្ថែមទៀត។

## តារាងប្រចាំសប្តាហ៍៖ ការចំណាយប្រាក់ហោប៉ៅប្រជាពលរដ្ឋខ្មែរលើសុខភាពពីឆ្នាំ២០០០ ដល់ឆ្នាំ២០១៥

ការចំណាយប្រាក់ហោប៉ៅប្រជាពលរដ្ឋខ្មែរទៅលើសុខភាព (ការចំណាយនេះមិនមែនជាជំនួយពីវិស័យសាធារណៈទេ) មានទំហំធំណាស់ធៀបនឹងការចំណាយលើផ្នែកសុខភាពសរុបនៅក្នុងប្រទេសកម្ពុជាពីឆ្នាំ២០០០ ដល់ឆ្នាំ២០១៥។

### ចំណែកនៃការចំណាយចេញពីប្រាក់ហោប៉ៅប្រជាពលរដ្ឋនៅក្នុងប្រទេសកម្ពុជា




ប្រភព៖ ធនាគារពិភពលោកឆ្នាំ២០១៩៖ ទិន្នន័យប្រទេសកម្ពុជា

ការឧបត្ថម្ភរបស់រាជរដ្ឋាភិបាលកម្ពុជា ទៅឱ្យប្រជាពលរដ្ឋសម្រាប់ការចំណាយទៅលើសុខភាពមានត្រឹមតែ២០% ប៉ុណ្ណោះ ក្នុងអំលុងឆ្នាំខាងលើ ខណៈដែលចំណែកដែលនៅសេសសល់គឺជាចំណែកឧបត្ថម្ភពីម្ចាស់ជំនួយក្រៅប្រទេស និងជំនួយអន្តរជាតិតាមរយៈអង្គការនានា។

## ព័ត៌មាន និងទិន្ន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

### មានការអំពាវនាវឱ្យមាន "ភាពជាដៃគូអឺរ៉ុប-ចិនដ៏រឹងមាំ" ក្នុងអំឡុងពេលដែលលោកប្រធានាធិបតីចិនស៊ីបានមកដល់ប្រទេសបារាំង

ប្រធានាធិបតីចិន លោក ស៊ីជីនពីង និងប្រធានាធិបតីបារាំង លោក អេម៉ានុយអែល ម៉ាក្រុង បានអំពាវនាវឱ្យមានភាពជាដៃគូដ៏រឹងមាំរវាងចិន និងសហភាពអឺរ៉ុប ខណៈដែលភាគីទាំងពីរបានជួបពិភាក្សាគ្នា នៅវិមានអេលីសេ កាលពីថ្ងៃចន្ទទី២៥ ខែមីនាកន្លងទៅនេះ។

សេចក្តីថ្លែងការណ៍នេះបានធ្វើឡើងបន្ទាប់ពីការចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពីថាមពលនុយក្លេអ៊ែរ ការផ្លាស់ប្តូរវប្បធម៌ ថាមពលស្អាត និងកិច្ចព្រមព្រៀងមួយដែលចិននឹងទិញយន្តហោះដឹកអ្នកដំណើរម៉ាក Airbus A320s ចំនួន ២៩០គ្រឿង និងយន្តហោះ ម៉ាក A350s ចំនួន ១០គ្រឿង ពីក្រុមហ៊ុនផលិតយន្តហោះរបស់អឺរ៉ុប។

ជារួម កិច្ចព្រមព្រៀងបានឈានដល់ការឯកភាពគ្នា ក្នុងអំឡុងពេលធ្វើទស្សនកិច្ច ដែលមានទំហំទឹកប្រាក់ ៤០ប៊ីលានដុល្លារ និងរួមបញ្ចូលកិច្ចព្រមព្រៀងមួយសម្រាប់ការនាំចេញមាន់ក្លាសេពីប្រទេសបារាំង ទៅកាន់ប្រទេសចិនផងដែរ។

ទោះបីជាលទ្ធផលពាណិជ្ជកម្មមានលក្ខណៈវិជ្ជមានក៏ដោយក៏សហភាពអឺរ៉ុបនៅតែមានការប្រយ័ត្នប្រយែង ចំពោះក្រុមហ៊ុនទូរគមនាគមន៍ដ៏ធំរបស់ចិន Huawei និងហានិភ័យសន្តិសុខដែលអាចកើតមានឡើងរបស់ក្រុមហ៊ុន

នេះ គឺចំពេលដែលមានរបាយការណ៍ពីមានការជៀតជ្រែកពីទីក្រុងប៉េកាំង ទៅលើប្រព័ន្ធទូរគមនាគមន៍។

## សេដ្ឋកិច្ចសហរដ្ឋអាមេរិក និងទុនបម្រុងសហព័ន្ធ

អ្នកព្យាករណ៍សេដ្ឋកិច្ចមើលឃើញពីភាពនៅទ្រឹងនៃសេដ្ឋកិច្ចអាមេរិក ដែលនេះឆ្លុះបញ្ចាំងថាគោលនយោបាយពាណិជ្ជកម្ម និងការថយចុះនៃសេដ្ឋកិច្ចសកលលោក គឺជាហានិភ័យដ៏ធំបំផុតសមាគមជាតិនៃសេដ្ឋវិទូពាណិជ្ជកម្ម បានចេញផ្សាយពីទស្សនវិស័យប្រចាំខែមីនារបស់ខ្លួនថ្មីៗនេះ ដោយបានរាយការណ៍អំពីលទ្ធផលនៃការស្ទង់មតិរបស់អ្នកព្យាករណ៍សេដ្ឋកិច្ចវិជ្ជាជីវៈចំនួន៥៥ នាក់។

ចក្ខុវិស័យរួមគ្នានោះគឺថា សេដ្ឋកិច្ចអាមេរិកបានឈានដល់ចំណុចជះត្រឡប់មកវិញ (Inflection point) ហើយកំណើនផលិតផលជាតិសរុបពិត នឹងធ្លាក់ចុះពី ២,៩% នៅឆ្នាំ ២០១៨ ដល់ ២,៤% ក្នុងឆ្នាំ២០១៩ និងដល់ ២% នៅឆ្នាំ ២០២០។

សម្រាប់មតិភាគច្រើន ការធ្លាក់ចុះដែលរំពឹងទុកនោះ គឺជាលទ្ធផលដែលជះឥទ្ធិពលពីគោលនយោបាយពាណិជ្ជកម្មអាមេរិក។ មនុស្សជាច្រើនបានគូសបញ្ជាក់ថា មានការព្រួយបារម្ភផ្នែកពាណិជ្ជកម្មបន្ថែមទៀត និងការធ្លាក់ចុះនៃសេដ្ឋកិច្ចពិភពលោក ដែលជាហានិភ័យសក្តានុពល។ មានមនុស្សតិចតួច(៦%)បានមើលឃើញថា សេដ្ឋកិច្ចអាចមានលក្ខណៈប្រសើរឡើងវិញ។ ក្រុមសេដ្ឋវិទូបានមើលឃើញថា អាចមានឱនភាពសេដ្ឋកិច្ចនៅដំណាច់ឆ្នាំ២០២០ ប្រមាណជា៣៥% ។

## ព័ត៌មានសម្រាប់សប្តាហ៍បន្ទាប់

ទិន្នន័យសម្រាប់សប្តាហ៍ខាងមុខនេះ រួមមានៈ អតិផរណានៅក្នុងប្រទេសកូរ៉េខាងត្បូង ឥណ្ឌូនេស៊ី និងអត្រានិកម្មភាពនៅតំបន់អឺរ៉ុប សហរដ្ឋអាមេរិក និងអេស្ប៉ាញ។

ខាងក្រោមគឺជាប្រតិទិនពេញលេញនៃការចេញនូវទិន្នន័យ និងការអភិវឌ្ឍ ដែលក្រុម FACT នឹងបន្តតាមដាននៅសប្តាហ៍ក្រោយៈ

<u>ថ្ងៃច័ន្ទ ទី០១ ខែមេសា</u>

- តុល្យភាពពាណិជ្ជកម្មរបស់កូរ៉េខាងត្បូង សម្រាប់ខែមីនា
- អតិផរណារបស់ថៃ សម្រាប់ខែមីនា
- អតិផរណារបស់ឥណ្ឌូណេស៊ី សម្រាប់ខែមីនា
- និកម្មភាពក្នុងតំបន់អឺរ៉ុប សម្រាប់ខែកុម្ភៈ
- អតិផរណាក្នុងតំបន់អឺរ៉ុប សម្រាប់ខែមីនា

<u>ថ្ងៃអង្គារ ទី០២ ខែមេសា</u>

- អតិផរណារបស់កូរ៉េខាងត្បូង សម្រាប់ខែមីនា
- ទំនុកចិត្តនៃអាជីវកម្មរបស់ថៃ សម្រាប់ខែមីនា

<u>ថ្ងៃពុធ ទី០៣ ខែមេសា</u>

- រូបិយប័ណ្ណបរទេសបម្រុងរបស់កូរ៉េខាងត្បូង សម្រាប់ខែមីនា
- រូបិយប័ណ្ណបរទេសបម្រុងរបស់តៃវ៉ាន់ សម្រាប់ខែមីនា
- សន្ទស្សន៍នៃការគ្រប់គ្រងការទិញ Nikkei របស់សឹង្ហបុរី សម្រាប់ខែមីនា

<u>ថ្ងៃព្រហស្បត្តិ៍ ទី០៤ ខែមេសា</u>

- គណនីចរន្តរបស់កូរ៉េខាងត្បូង សម្រាប់ខែកុម្ភៈ
- ទំនុកចិត្តអតិថិជននៅថៃ សម្រាប់ខែមីនា

- តុល្យភាពពាណិជ្ជកម្មរបស់ម៉ាឡេស៊ី សម្រាប់ខែកុម្ភៈ

<u>ថ្ងៃសុក្រ ទី០៥ ខែមេសា</u>

- អតិផរណារបស់ហ្វីលីពីន សម្រាប់ខែមីនា
- ផលិតកម្មឧស្សាហកម្មរបស់ហ្វីលីពីន សម្រាប់ខែកុម្ភៈ
- ទំនុកចិត្តអ្នកប្រើប្រាស់របស់ឥណ្ឌូណេស៊ី សម្រាប់ខែមីនា
- និកម្មភាពនៅអាមេរិក សម្រាប់ខែមីនា៕